ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៧២៥ សរណន.កសក

# សារាចរណែនាំ

## ស្តីពី

## វិធានការ អនុវត្តការងារបង្កបង្កើនផលស្រូវប្រាំង ឆ្នាំ ២០០៤-២០០៥

នៅរដូវវស្សាឆ្នាំ ២០០៤ នេះជាទូទៅចាប់តាំងពីដើមរដូវមក អាកាសធាតុមានលក្ខណៈអំណោយផលជាបង្គួរសមស្របដល់ការងារបង្កបង្កើនផល ទោះបីជាមានភាពរាំងស្ងួតនៅតំបន់ខ្លះក្នុងខេត្តមួយចំនួនដូចជាខេត្តតាកែវ កំពត ព្រៃវែង ស្វាយរៀង និងខេត្តកំពង់ចាមក៏ដោយ។ ដោយឡែកតែខេត្តកំពង់ស្ពឺ មួយប៉ុណ្ណោះដែលភាពរាំងស្ងួតបានអូសបន្លាយចាប់តាំងពីដើមរដូវ រហូតដល់ពេលបច្ចុប្បន្ន។

ដោយមានការយកចិត្តទុកដាក់អន្តរាគមន៍ តាមគ្រប់មធ្យោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាដើម្បីជួយដល់កសិករនោះ ផ្ទៃដីនៃការងារបង្កបង្កើនផលស្រូវ រដូវវស្សាឆ្នាំនេះសំរេចបានស្មើនឹងកំរិតរដូវវស្សាឆ្នាំ ២០០៣កន្លងទៅ។ ដំណាំស្រូវបានលូតលាស់ បែកគុម្ព គួរជាទី ពេញចិត្ត។

ប៉ុន្តែចាប់តាំងពីពាក់កណ្តាលខែតុលាមក នៅទូទាំងប្រទេស ភ្លៀងបានផ្អាក និងឈានទៅរកការបញ្ចប់ទាំងស្រុង ធ្វើអោយដំណាំស្រូវដែលកំពុងលូតលាស់ល្អ ហើយភាគច្រើនបានឈានចូលដំណាក់កាលផើម និងកំណក្វ ហើយនោះ ត្រូវទទួលរងការប៉ះពាល់ធ្ងន់ធ្ងរ និងឈានដល់ការខូចខាតស្ទើរតែទាំងស្រុង។ ប្រឈមមុខនឹងសភាពការនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងប្រើប្រាស់អស់លទ្ធភាពនូវមធ្យោបាយដែលមាន ដើម្បីសង្គ្រោះការខូចខាត។ ការបូមបាចបាន និងកំពុងបន្តដំណើរការពីប្រភពទឹកទាំងឡាយដែលមានរួមទាំង ស្ទឹង អូរ បឹងបួរទាំងឡាយដែលភាគច្រើនក៏ជាប្រភពទឹកសំរាប់ស្រូវរដូវប្រាំងខាងមុខផងដែរ។

ទន្ទឹមនឹងនេះ ឆ្នាំនេះទឹកទន្លេមេគង្គបានស្រកចុះយ៉ាងលឿនរួមទាំងទឹក ស្ទឹង បឹងបួរនានាផង ហើយគួបផ្សំនឹងការបូមបាច សង្គ្រោះស្រូវវស្សានាពេលនេះ ធ្វើអោយបរិមាណទឹកថយចុះ និងបណ្តាលអោយមានការខ្វះខាតទឹកសំរាប់ស្រូវប្រាំង នាពេលខាងមុខ។

ក្នុងគោលបំណងដើម្បីធានាអោយសំរេចបាន តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងធានាសុវត្ថិភាពស្បៀង ជាពិសេសកាត់បន្ថយការប្រឈមមុខនឹងការខ្វះខាតទឹកនៅរដូវប្រាំងខាងមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត-ក្រុងទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួន ដូចខាងក្រោម៖

- ពិនិត្យលទ្ធភាពជាក់ស្តែងប្រភពទឹកសំរាប់រដូវប្រាំង ដើម្បីកំណត់អោយបានច្បាស់នូវទីតាំង និងផ្ទៃដីដែលអាចធានាការស្រោចស្រពបាន ហើយណែនាំដល់កសិករមុនចាប់ពីពេលដកស្ទូងរហូតដល់ប្រមូលផល
- បំផុសប្រជាកសិករ អោយបង្វែរផ្ទៃដីស្រូវប្រាំង ដែលមិនអាចធានាទឹកស្រោចស្រពបាន ទៅដាំដំណាំស្បៀង រួមផ្សំដ៏ទៃទៀតដែលត្រូវការទឹកតិចជាងដំណាំស្រូវ ដូចជា សណ្តែក ដំឡូងជ្វា ដំឡូងមី ត្រាវ ។ល។
- អប់រំបណ្តុះបណ្តាល បច្ចេកទេសដាំដុះដល់ប្រជាកសិករដើម្បីធានាការបង្កើនទិន្នផលអោយបានខ្ពស់ជាអតិបរិមា
- បំផុសប្រជាកសិករអោយរកមុខរបរផ្សេងៗបន្ថែមទៀត តាមស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាន នីមួយៗតាមគោលការណ៍ "ភូមិមួយផលិតផលមួយ "។

ជារួមអង្គភាពថ្នាក់កណ្តាល និងមូលដ្ឋានខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ត្រូវម្ចាស់ការបន្តយកចិត្តទុកដាក់តាមដានសភាពការ និងជំរុញការងារផលិតកម្មជាប្រចាំ ព្រមទាំងរួមសហការដោះស្រាយការលំបាកផ្សេងៗជាមួយកសិករក៏ដូចជាមួយផ្នែកពាក់ព័ន្ធ ហើយរាយការណ៍អោយបានទាន់ពេលវេលា។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុងត្រូវមានវិធានការអនុវត្តអោយបានសមស្របដើម្បីធានាប្រសិទ្ធភាពក្នុងការសំរេចបាននូវបរិមាណផលិតផលកសិកម្មខ្ពស់នៅរដូវប្រាំង ២០០៤-២០០៥ សំដៅ ធានាសុវត្ថិភាពស្បៀង រួមចំណែកពង្រឹងដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ពន្លឿនកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ខែ ធ្នូ ឆ្នាំ ២០០៤

ចន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ